M0075640-07 (kh-km)
ខែកក្កដា ឆ្នាំ 2020

# សៀវភៅណែនាំស្ដីពីប្រតិបត្តិការ និងការថែទាំជួសជុល

## Product Link® PLG641, PLG641V2, និង PLG601 សម្រាប់ប្រព័ន្ធម៉ាស៊ីនភ្លើង

PL6 1-UP (ការគ្រប់គ្រងម៉ាស៊ីន
និងផលិតផលណែនាំ)

ភាសា៖ ការណែនាំដើម

ស្កេនដើម្បីចូលប្រើប្រាស់ព័ត៌មានចុងក្រោយបំផុតអំពីសេវាកម្ម ជាវមេឌៀបន្ថែម
និងទិញគ្រឿងបន្លាស់សុទ្ធរបស់ **Cat®** ។

CAT®

# ព័ត៌មានអំពីសុវត្ថិភាពសំខាន់ៗ

គ្រោះថ្នាក់ភាគច្រើនដែលពាក់ព័ន្ធនឹងប្រតិបត្តិការគ្រឿងចក្រ ការថែទាំ និងការជួសជុល គឺបណ្ដាលមកពីការមិនគោរពវិធានសុវត្ថិភាពជាមូលដ្ឋាន ឬការប្រុងប្រយ័ត្នជាមុន។ ជារឿយៗ គ្រោះថ្នាក់អាចជៀសវាងបានតាមរយៈការដឹងពីស្ថានភាពដែលអាចបង្កគ្រោះថ្នាក់ មុនពេលគ្រោះថ្នាក់កើតឡើង។ គេត្រូវតែប្រុងប្រយ័ត្នចំពោះគ្រោះថ្នាក់ដែលអាចកើតឡើង ដែលរួមមានកត្តាមនុស្សដែលអាចប៉ះពាល់ដល់សុវត្ថិភាព។ មនុស្សម្នាក់នេះក៏គួរមានការបណ្ដុះបណ្ដាលជំនាញ និងមានឧបករណ៍ដែលចាំបាច់ ដើម្បីបំពេញមុខងារទាំងនេះឲ្យបានត្រឹមត្រូវផងដែរ។

**ប្រតិបត្តិការ ការដាក់ប្រេងរំអិល ការថែទាំ ឬការជួសជុលគ្រឿងចក្រមិនបានត្រឹមត្រូវ អាចបង្កគ្រោះថ្នាក់ ហើយអាចបណ្ដាលឲ្យមានរបួស ឬស្លាប់។**

**មិនត្រូវធ្វើប្រតិបត្តិការ ឬធ្វើការដាក់ប្រេងរំអិល ការថែទាំ ឬការជួសជុលចំពោះគ្រឿងចក្រនេះឡើយ រហូតដល់អ្នកបញ្ជាក់ថា អ្នកត្រូវបានអនុញ្ញាតឲ្យអនុវត្តការងារនេះ ហើយបានអាននិងយល់ពីព័ត៌មានអំពីប្រតិបត្តិការ ការដាក់ប្រេងរំអិល ការថែទាំ និងការជួសជុល។**

ការប្រុងប្រយ័ត្ន និងការព្រមានជាមុនអំពីបញ្ហាសុវត្ថិភាព ត្រូវបានផ្ដល់នៅក្នុងសៀវភៅណែនាំនេះ និងនៅលើគ្រឿងចក្រ។ ប្រសិនបើមិនយកចិត្តទុកដាក់ចំពោះការព្រមានអំពីគ្រោះថ្នាក់ទាំងនេះ របួសរាងកាយ ឬស្លាប់អាចនឹងកើតមានឡើងចំពោះអ្នក ឬអ្នកដទៃ។

គ្រោះអន្តរាយនានាត្រូវដាក់សម្គាល់ដោយ "រូបសញ្ញាប្រុងប្រយ័ត្នអំពីសុវត្ថិភាព" និងបន្ទាប់មកដោយ "ពាក្យសញ្ញា" ដូចជា "DANGER (គ្រោះថ្នាក់)" "WARNING (ព្រមាន)" ឬ "CAUTION (ប្រយ័ត្ន)" ។ ស្លាក "WARNING" (ការព្រមាន) ឲ្យប្រយ័ត្នអំពីសុវត្ថិភាព ត្រូវបានបង្ហាញខាងក្រោម។

**⚠ ការព្រមាន**

អត្ថន័យនៃនិមិត្តសញ្ញាឲ្យប្រយ័ត្នអំពីសុវត្ថិភាពនេះមានដូចខាងក្រោម៖

**ប្រយ័ត្ន! សូមប្រយ័ត្ន! អាចប៉ះពាល់សុវត្ថិភាពរបស់អ្នក។**

សារដែលលេចឡើងខាងក្រោមសេចក្ដីព្រមាន ពន្យល់អំពីគ្រោះថ្នាក់ និងអាចជាសំណេរ ឬជារូបភាព។

បញ្ជីមិនពេញលេញស្ដីពីប្រតិបត្តិការទាំងឡាយដែលអាចបណ្ដាលឲ្យខូចផលិតផល ត្រូវបានសម្គាល់ដោយស្លាក "NOTICE" ដែលស្ថិតនៅលើផលិតផលនោះ និងនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ។

**ក្រុមហ៊ុន Caterpillar មិនអាចរៀបរាប់អំពីស្ថានភាពដែលអាចបង្កគ្រោះថ្នាក់ទាំងអស់បានឡើយ។ ដូចនេះ ការព្រមាននៅក្នុងឯកសារបោះពុម្ពផ្សាយនេះ និងការព្រមាននៅលើគ្រឿងចក្រ មិនបានរួមបញ្ចូលគ្រប់ស្ថានភាពទាំងអស់ទេ។ អ្នកមិនត្រូវប្រើគ្រឿងចក្រនេះតាមវិធីណាមួយខុសពីអ្វីដែលបានណែនាំនៅក្នុងកូនសៀវភៅណែនាំនេះឡើយ លុះត្រាតែអ្នកច្បាស់ក្នុងចិត្តជាមុនថា អ្នកបានគិតពិចារណាលើវិធាន និងការប្រុងប្រយ័ត្នអំពីសុវត្ថិភាពទាំងអស់ដែលពាក់ព័ន្ធនឹងប្រតិបត្តិការគ្រឿងចក្រនេះនៅទីតាំងប្រើប្រាស់នីមួយៗ រួមទាំងវិធាន និងការប្រុងប្រយ័ត្នអំពីសុវត្ថិភាពនៅតាមទីតាំងជាក់លាក់នៅក្នុងការដ្ឋាន។ ប្រសិនបើឧបករណ៍ ទម្រង់ការ វិធីសាស្ត្រធ្វើការងារ ឬបច្ចេកទេសប្រតិបត្តិការមិនទទួលបានការណែនាំជាក់លាក់ពី Caterpillar ទេ លោកអ្នកត្រូវតែប្រាកដដោយខ្លួនឯងថា វាមានសុវត្ថិភាពចំពោះលោកអ្នក និងអ្នកដទៃ។ លោកអ្នកក៏ត្រូវប្រាកដដែរថា លោកអ្នកត្រូវបានអនុញ្ញាតឲ្យអនុវត្តការងារនេះ ហើយក៏ត្រូវធានាទៀតដែរថា គ្រឿងចក្រនឹងមិនខូច ឬក៏គ្មានសុវត្ថិភាពដោយសារប្រតិបត្តិការ ការដាក់ប្រេងរំអិល ការថែទាំ ឬវិធីជួសជុលដែល លោកអ្នកចង់ធ្វើផងដែរ។**

ព័ត៌មាន លក្ខណៈបច្ចេកទេស និងរូបភាពនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ គឺជាព័ត៌មានមូលដ្ឋានដែលមាននៅពេលចងក្រងឯកសារបោះពុម្ពផ្សាយ។ លក្ខណៈបច្ចេកទេស តំណឹង សម្ពាធ រង្វាស់ ការលៃតម្រូវ រូបភាព និងចំណុចផ្សេងទៀត អាចត្រូវបានផ្លាស់ប្ដូរគ្រប់ពេលវេលា។ ការផ្លាស់ប្ដូរទាំងនេះអាចប៉ះពាល់ដល់សេវាកម្មគ្រឿងចក្រដែលបានផ្ដល់ជូន។ សូមស្វែងយល់ឲ្យបានច្បាស់លាស់ និងទទួលយកព័ត៌មានថ្មីៗបំផុត នៅមុនពេលអ្នកចាប់ផ្ដើមការងារណាមួយ។ អ្នកចែកចាយ Cat មានព័ត៌មានថ្មីៗបំផុត។

---

សម្គាល់

**ពេលត្រូវការផ្លាស់ប្ដូរគ្រឿងបន្លាស់សម្រាប់ផលិតផលនេះ Caterpillar សូមណែនាំឲ្យប្រើប្រាស់គ្រឿងបន្លាស់របស់ Caterpillar។**

**ផ្នែកដទៃទៀតអាចមិនឆ្លើយតបតាមព័ត៌មានលម្អិតគ្រឿងបរិក្ខារដើមមួយចំនួន។**

**នៅពេលប្ដូរគ្រឿង ម្ចាស់/អ្នកប្រើប្រាស់ម៉ាស៊ីនគួរតែប្រាកដថាម៉ាស៊ីននៅតែអនុលោមតាមសេចក្ដីតម្រូវដែលអាចអនុវត្តបានទាំងអស់។**

---

**នៅសហរដ្ឋអាមេរិក ការថែទាំ ការប្ដូរគ្រឿងបន្លាស់ ឬការជួសជុលឧបករណ៍ និង ប្រព័ន្ធគ្រប់គ្រងការបំភាយផ្សែង អាចធ្វើឡើងដោយគ្រឹះស្ថានជួសជុលណាមួយ ឬបុគ្គលណាម្នាក់តាមការជ្រើសរើសរបស់ម្ចាស់គ្រឿងចក្រ។**

# តារាងមាតិកា

បុព្វកថា ....................................................................4

## ផ្នែកសុវត្ថិភាព

សញ្ញានិងតែមសុវត្ថិភាព។...................................................5

ព័ត៌មានអំពីគ្រោះអន្តរាយទូទៅ.............................................6

## ផ្នែកប្រតិបត្តិការ

ប្រតិបត្តិការ.....................................................................7

## ព័ត៌មានអនុលោមតាមបទប្បញ្ញត្តិ

សមាសភាគប្រេកង់វិទ្យុ ......................................................8

## ផ្នែកលិបិក្រម

លិបិក្រម ..................................................................... 14

# បុព្វកថា

## ព័ត៌មាននៃឯកសារ

កូនសៀវភៅណែនាំនេះ គួរតែរក្សាទុកនៅបន្ទប់របស់ប្រតិបត្តិករ នៅកន្លែងទុកដាក់ឯកសារ ឬកន្លែងរក្សាទុកឯកសារនៅខាងក្រោយខ្នងកៅអី។

កូនសៀវភៅណែនាំនេះមានព័ត៌មានអំពីសុវត្ថិភាព ការណែនាំអំពីប្រតិបត្តិការ និងអនុសាសន៍នៃការថែទាំ។

រូបថតឬរូបភាពមួយចំនួននៅក្នុងការបោះពុម្ពផ្សាយនេះបង្ហាញព័ត៌មានលម្អិត ឬឯកសារភ្ជាប់ដែលអាចខុសគ្នា ពីផលិតផលរបស់លោកអ្នក។

ការបន្តកែលម្អ និងការវិវឌ្ឍនៃការឌីស្សាញផលិតផលនេះ អាចនឹងបណ្តាលឲ្យមានការផ្លាស់ប្តូរចំពោះផលិតផលរបស់អ្នក ដែលមិនមាននៅក្នុងឯកសារបោះពុម្ពផ្សាយនេះ។ សូមអាន ស្វែងយល់ និងរក្សាទុកកូនសៀវភៅណែនាំនេះជាមួយនឹងផលិតផល។

ប្រសិនបើមានសំណួរទាក់ទងនឹងផលិតផលរបស់អ្នក ឬឯកសារបោះពុម្ពផ្សាយនេះ សូមពិគ្រោះជាមួយអ្នកចែកចាយផលិតផល Cat របស់លោកអ្នកដើម្បីទទួលបានព័ត៌មានថ្មីៗបំផុត។

## សុវត្ថិភាព

ផ្នែកសុវត្ថិភាពមានរៀបរាប់អំពីការប្រុងប្រយ័ត្នពីសុវត្ថិភាពសំខាន់ៗ។ លើសពីនេះទៀត ផ្នែកនេះកំណត់ប្រភេទអត្ថបទ និងទីតាំងសញ្ញា និងស្លាកសញ្ញាព្រមានដែលបានប្រើនៅលើគ្រឿងចក្រ។

## ប្រតិបត្តិការ

ផ្នែកប្រតិបត្តិការនេះជាឯកសារយោងសម្រាប់ប្រតិបត្តិករថ្មី និងជាការរំលឹកសម្រាប់ប្រតិបត្តិករដែលមានបទពិសោធន៍។ ផ្នែកនេះរួមមានការពិភាក្សាអំពីឧបករណ៍វាស់ កុងតាក់ ឧបករណ៍បញ្ជាផលិតផល ឧបករណ៍បញ្ជាគ្រឿងភ្ជាប់ និងព័ត៌មានអំពីការសរសេរកម្មវិធី។

រូបថត និងរូបភាពណែនាំប្រតិបត្តិករតាមនិតិវិធីត្រឹមត្រូវ នៃការត្រួតពិនិត្យការបញ្ឆេះ ប្រតិបត្តិការ និងការបញ្ឈប់ផលិតផល។

បច្ចេកទេសប្រតិបត្តិការដែលមានក្នុងឯកសារបោះពុម្ពផ្សាយនេះ ជាឯកសារមូលដ្ឋាន។ ជំនាញ និងបច្ចេកទេសកាន់តែរីកចម្រើន នៅពេលប្រតិបត្តិករកើនចំណេះដឹងផ្នែកផលិតផល និងផ្នែកសមត្ថភាពរបស់ផលិតផល។

## ការថែទាំជួសជុល

ផ្នែកការថែទាំជួសជុលគឺជាការណែនាំសម្រាប់ការថែទាំឧបករណ៍។

# ផ្នែកសុវត្ថិភាព

i08118663

## សញ្ញា និងស្លាកសញ្ញាសុវត្ថិភាព

កូដ **SMCS៖** 7606

**⚠ ការព្រមាន**

ហាមប្រតិបត្តិការ ឬធ្វើការងារលើគ្រឿងចក្រនេះ បើលោកអ្នកមិនបានអាន និងស្វែងយល់អំពីសេចក្តីណែនាំនិងការព្រមាន ដែលមាននៅក្នុងសៀវភៅណែនាំស្តីពីប្រតិបត្តិការ និងការថែទាំជួសជុលទេនោះ។ ការមិនអនុវត្តតាមសេចក្តីណែនាំ ឬមិនបានយកចិត្តទុកដាក់លើការព្រមានទាំងនេះអាចបណ្តាលឲ្យមានរបួសឬស្លាប់បាន។ ទាក់ទងអ្នកចែកចាយ **Caterpillar** របស់អ្នកជំនួសឲ្យកូនសៀវភៅណែនាំ។ ការយកចិត្តទុកដាក់សមស្របគឺជាការទទួលខុសត្រូវរបស់អ្នក។

**⚠ ការព្រមាន**

ប្រតិបត្តិការផ្លែតហ្វមប្រកលូកចូលមិនត្រឹមត្រូវអាចបណ្តាលឲ្យរងរបួសឬស្លាប់បាត់បង់ជីវិត។ ប្រតិបត្តិការត្រូវតែអនុវត្តភារកិច្ចរបស់ខ្លួនឲ្យបានត្រឹមត្រូវ និងអនុវត្តតាមលំណែនាំ និងគោលការណ៍ទាំងអស់សម្រាប់គ្រឿងចក្រនិងផ្លែតហ្វមប្រកលូកចូលនេះ។

**⚠ ការព្រមាន**

ការបញ្ឆេះម៉ាស៊ីនដោយចៃដន្យអាចធ្វើឲ្យអ្នកដែលធ្វើការនៅលើគ្រឿងចក្ររងរបួស ឬគ្រោះថ្នាក់ដល់ស្លាប់។

ដើម្បីចៀសវាងគ្រឿងចក្របញ្ឆេះដោយចៃដន្យ ចូរផ្តាច់ខ្សែកាបថ្មចេញពីតំណក្បាលថ្មអវិជ្ជមាន **(–)**។ ចូររុំស្កុតជុំវិញផ្ទៃលោហៈចុងខ្សែកាបថ្មដែលផ្តាច់ចេញទាំងអស់ ដើម្បីការពារ ប៉ះជាមួយផ្ទៃលោហៈដទៃទៀតដែលអាចបើកដំណើរការប្រព័ន្ធអគ្គិសនីម៉ាស៊ីន។

កាច់កុងតាក់ផ្តាច់ថ្មទៅទីតាំង **OFF** ហើយដកសោចេញ។

ដាក់ស្លាកសេចក្តីណែនាំពិសេស **S9HO7332** "កុំធ្វើប្រតិបត្តិការ" នៅត្រង់កុងតាក់បញ្ឆេះ និងកន្លែងផ្តាច់ថ្មដើម្បីប្រាប់បុគ្គលិកថាម៉ាស៊ីនកំពុងដំណើរការ។

## សារសុវត្ថិភាព

ស្លាកព្រមាននៅក្នុងរូបភាពទី 1 អាចឃើញមាននៅក្នុងទីតាំងមួយដូចជាប៉ាណូបរិធានស្ទង់ ឬផ្ទាំងបញ្ជា។ ប្រតិបត្តិករអាចមើលឃើញស្លាកព្រមានបានច្បាស់នៅអំឡុងពេល ប្រតិបត្តិការឧបករណ៍ធម្មតា។



រូបភាព 1 g06553526

តែម

**⚠ ការព្រមាន**

កំណត់សម្គាល់៖ បរិក្ខាររបស់យើងអាចត្រូវបានបំពាក់ដោយឧបករណ៍ប្រាស្រ័យទាក់ទង **Caterpillar Product Link** ។ នៅពេលកំពុងប្រើប្រាស់កិបអគ្គិសនីសម្រាប់ប្រតិបត្តិការបំផ្ទុះ ឧបករណ៍ប្រេកង់វិទ្យុអាចរំខានដល់កិបអគ្គិសនីសម្រាប់ធ្វើឲ្យផ្ទុះ ដែលអាចបណ្តាលឲ្យរងរបួសធ្ងន់ធ្ងរ ឬស្លាប់។ ឧបករណ៍ទាក់ទង **Product Link** គួរតែបិទនៅក្នុងចម្ងាយដែលបានកំណត់ស្ថិតក្រោមសេក្តីតម្រូវបទប្បញ្ញត្តិមូលដ្ឋាន ឬថ្នាក់ជាតិ។ ក្នុងករណីមិនមានសេក្តីតម្រូវបទប្បញ្ញត្តិ ក្រុមហ៊ុន **Caterpillar** សូមណែនាំឲ្យអ្នកប្រើប្រាស់ចុងក្រោយ អនុវត្តតាមការវាយតម្លៃហានិភ័យផ្ទាល់ខ្លួនរបស់ពួកគេដើម្បីកំណត់ចម្ងាយប្រតិបត្តិការដែលមានសុវត្ថិភាព។

តំបន់ផ្ទុះត្រូវបានកំណត់ជាតំបន់ដែលមានវត្ថុផ្ទុះក្នុងអំឡុងពេលផ្ទុក។ រួមបញ្ចូលគឺបរិវេណដែលបង្កើតឡើងដោយរណ្តៅផ្ទុះដែលបានផ្ទុក។

ប្រសិនបើវិធីសាស្ត្រដែលតម្រូវខាងក្រោមនេះជាវិធីសាស្ត្រដែលបានស្នើដើម្បីបិទឧបករណ៍ទំនាក់ទំនង Product Link របស់ Caterpillar ៖

- ផ្តាច់ឧបករណ៍ទាក់ទង Caterpillar Product Link ពីប្រភពថាមពល។ សកម្មភាពនេះត្រូវបានអនុវត្តដោយផ្តាច់ខ្សែភ្លើងនៅត្រង់វិទ្យុ Product Link។

## តែមផ្សេងទៀត

ស្លាកព្រមាននៅក្នុងរូបភាពទី 2 អាចរកឃើញនៅក្នុងទីតាំងដូចជាប៉ាណូបរិធានស្ទង់ ឬផ្ទាំងបញ្ជា។ ប្រតិបត្តិករអាចមើលឃើញស្លាកព្រមានបានច្បាស់នៅអំឡុងពេល ប្រតិបត្តិការឧបករណ៍ធម្មតា។



រូបភាព 2 g06553500

ស្លាកក្នុងរូបភាពទី 2 មានគោលបំណងប្រាប់ដល់ប្រតិបត្តិករថាបរិក្ខារនេះត្រូវបានបំពាក់ដោយឧបករណ៍បញ្ជូនឥតខ្សែ។ ដូច្នេះ ទិន្នន័យដែលទាក់ទងនឹងគ្រឿងបរិក្ខារនេះ លក្ខខណ្ឌគ្រឿងបរិក្ខារ និងប្រតិបត្តិការគ្រឿងបរិក្ខារកំពុងត្រូវបញ្ជូនដោយឧបករណ៍ទំនាក់ទំនង Caterpillar Product Link ទៅកាន់ក្រុមហ៊ុន Caterpillar និងត្រូវទាក់ទងទៅកាន់អតិថិជន និងឈ្មួញចែកចាយក្រុមហ៊ុន Caterpillar តាមរយៈអ៊ីនធើណេតអ្នកប្រើប្រាស់។ ទិន្នន័យនេះត្រូវបានប្រើប្រាស់ដើម្បីបម្រើអតិថិជនឲ្យកាន់តែប្រសើរឡើង និងកែលម្អផលិតផល និង សេវាកម្ម Caterpillar។ ប្រអប់លេខព័ត៌មានដែលប្រើឧបករណ៍ទាក់ទង Caterpillar Product Link គឺត្រូវអនុវត្តទៅតាមច្បាប់ដែលអាចខុសគ្នាតាមទីកន្លែង។

សម្រាប់ព័ត៌មានបន្ថែម សូមអានកូនសៀវភៅណែនាំស្ដីពីប្រតិបត្តិការនិងការថែទាំជួសជុល លេខ M0075640 ផ្នែក "ប្រតិបត្តិការ" និងកូនសៀវភៅណែនាំស្ដីពីប្រតិបត្តិការនិងការថែទាំជួសជុល លេខ M0075640 ផ្នែក "ការអនុលោមតាមបទប្បញ្ញត្តិ"។

i06790240

## ព័ត៌មានអំពីគ្រោះថ្នាក់ទូទៅ

កូដ **SMCS៖** 7606

**⚠ ការព្រមាន**

**ហាមប្រតិបត្តិការ ឬធ្វើការងារលើគ្រឿងចក្រនេះ បើលោកអ្នកមិនបានអាន និងស្វែងយល់អំពីសេចក្តីណែនាំនិងការព្រមាន ដែលមាននៅក្នុងសៀវភៅណែនាំស្តីពីប្រតិបត្តិការ និងការថែទាំជួសជុលទេនោះ។ ការមិនអនុវត្តតាមសេចក្តីណែនាំ ឬមិនបានយកចិត្តទុកដាក់លើការព្រមានទាំងនេះអាចបណ្តាលឲ្យមានរបួសឬស្លាប់បាន។ ទាក់ទងអ្នកចែកចាយ Caterpillar របស់អ្នកជំនួសឲ្យកូនសៀវភៅណែនាំ។ ការយកចិត្តទុកដាក់សមស្របគឺជាការទទួលខុសត្រូវរបស់អ្នក។**

## បុព្វកថា

ឯកសារនេះគឺជាការបន្ថែមដល់សៀវភៅណែនាំអំពីប្រតិបត្តិការ និងការជួសជុលថែទាំបរិក្ខារ។ ភ្ជាប់ឯកសារនេះជាអចិន្ត្រៃយ៍ទៅក្នុងសៀវភៅណែនាំស្តីពីប្រតិបត្តិការ និងការថែទាំជួសជុលគ្រឿងបរិក្ខារ។

## សេចក្តីផ្តើម

ឯកសារនេះផ្តល់ព័ត៌មានអំពីប្រតិបត្តិការនៃឧបករណ៍ទាក់ទង Caterpillar Product Link ។

ប្រតិបត្តិការបរិក្ខារ និងការជួសជុលថែទាំបរិក្ខារនេះមិនត្រូវធ្វើឡើងឡើយ ប្រសិនបើមិនទាន់បានអានសេចក្តីណែនាំ និងការព្រមាននៅក្នុងសៀវភៅណែនាំអំពីប្រតិបត្តិការ និងការជួលជុលថែទាំបរិក្ខារនេះ និងមិនទាន់បានយល់អំពីការណែនាំ និងការព្រមាននេះទេនោះ។ ខ្លឹមសារនៃឯកសារនេះត្រូវតែយល់មុនពេលបរិក្ខារដែលបំពាក់ដោយឧបករណ៍ទាក់ទងរបស់ Caterpillar Product Link ដំណើរការ។

# ផ្នែកប្រតិបត្តិការ ប្រតិបត្តិការ

i08118597

## ទិដ្ឋភាពទូទៅប្រព័ន្ធ

កូដ **SMCS៖** 7606

គួរតែបំពាក់ PLG641, PLG641V2, និង PLG601 នៅក្នុងទីកន្លែងដែលមានសុវត្ថិភាពដើម្បីបង្ការកុំឲ្យគេចូលប្រើឧបករណ៍នេះដោយគ្មានការអនុញ្ញាត។

ឧបករណ៍ទាក់ទងតំណផលិតផល Cat ប្រើប្រាស់បច្ចេកវិទ្យាចល័ត និង/ឬផ្កាយរណប ដើម្បីទាក់ទងជាមួយព័ត៌មានអំពីបរិក្ខារ។ ព័ត៌មាននេះត្រូវបញ្ជូនទៅកាន់ Cat, អ្នកចែកចាយផលិតផល Cat និងអតិថិជនរបស់ Cat។ ឧបករណ៍ទំនាក់ទំនង Cat Product Link មានគ្រឿងទទួលផ្កាយរណប (GPS) ប្រព័ន្ធកំណត់ទីតាំងសកល មួយ។

សមត្ថភាពទាក់ទងពីរផ្លូវរវាងបរិក្ខា និងអ្នកប្រើពីចម្ងាយអាចប្រើបានជាមួយឧបករណ៍ទាក់ទងតំណផលិតផល Cat ។ អ្នកប្រើប្រាស់ពីចម្ងាយអាចជាអ្នកចែកចាយ ឬអតិថិជន។

**កំណត់ចំណាំ៖** ឧបករណ៍ Product Link ទាំងអស់ត្រូវតែស្ថិតនៅចម្ងាយជាង 200 ម.ម (7.87 inch) ពីប្រតិបត្តិករម៉ាស៊ីន ដើម្បីអនុលោមទៅតាមបទប្បញ្ញត្តិ FCC សម្រាប់សុវត្ថិភាពរាងកាយមនុស្ស RF។

## ការផ្សព្វផ្សាយទិន្នន័យ

ទិន្នន័យដែលទាក់ទងនឹងគ្រឿងបរិក្ខារនេះ លក្ខខណ្ឌនៃគ្រឿងបរិក្ខារ និងប្រតិបត្តិការគ្រឿងបរិក្ខារកំពុងត្រូវបញ្ជូនដោយឧបករណ៍ទំនាក់ទំនង Cat Product Link ទៅកាន់ Cat និងបញ្ជូនទៅកាន់អតិថិជននិងអ្នកចែកចាយផលិតផល Cat ដោយអ៊ីនធើណេតសម្រេចអ្នកប្រើប្រាស់។ ទិន្នន័យនេះត្រូវបានប្រើប្រាស់ដើម្បីបម្រើអតិថិជនឲ្យកាន់តែប្រសើរឡើង និងកែលម្អគ្រឿងចាក់ និង សេវាកម្ម Cat។ ព័ត៌មានដែលបានបញ្ជូនរួមមាន៖ លេខសេរីបរិក្ខារ ទីតាំងបរិក្ខារ និងទិន្នន័យប្រតិបត្តិការ ដូចជា៖ កូដកំហុស ទិន្នន័យនៃការបញ្ចេញឧស្ម័នពុល ការប្រើប្រាស់ប្រេងឥន្ធនៈ ម៉ោងនៅលើកុងទ័រប្រើប្រាស់ លេខកំណែសូហ្វែរ និង ហាដវែរ ព្រមទាំងគ្រឿងភ្ជាប់ដែលបានដំឡើង។

Cat និង/ឬអ្នកចែកចាយផលិតផល Cat អាចប្រើប្រាស់ព័ត៌មាននេះសម្រាប់គោលបំណងផ្សេងៗ។ សូមមើលបញ្ជីខាងក្រោមសម្រាប់លទ្ធភាពនៃការប្រើប្រាស់៖

- ការផ្តល់សេវាកម្មជូនអតិថិជន និង/ឬបរិក្ខារ
- ការត្រួតពិនិត្យ ឬ ការថែទាំប្រព័ន្ធ Product Link
- ត្រួតពិនិត្យសុខភាព ឬប្រសិទ្ធពលនៃគ្រឿងបរិក្ខារ
- ការជួយថែទាំបរិក្ខារ និង/ឬ កែលម្អប្រសិទ្ធភាពនៃគ្រឿងបរិក្ខារ
- ការវាយតម្លៃ ឬការកែលម្អគ្រឿងចាក់ និងសេវាកម្ម Cat
- ការអនុលោមតាមតម្រូវការច្បាប់ និងការបញ្ជារបស់តុលាការដែលមានសុពលភាព
- ការធ្វើការស្រាវជ្រាវទីផ្សារ
- ការផ្តល់ជូនអតិថិជននូវគ្រឿងចាក់ និង សេវាកម្មថ្មីៗ

Caterpillar អាចចែករំលែកព័ត៌មានដែលបានប្រមូលខ្លះ ឬ ទាំងអស់ជាមួយនឹងក្រុមហ៊ុនសម្ព័ន្ធរបស់ Caterpillar អ្នកចែកចាយ និងតំណាងដែលទទួលសិទ្ធិ។ Caterpillar នឹងមិនលក់ ឬជួលព័ត៌មានដែលប្រមូលបានទៅឲ្យភាគីទីបីផ្សេងណាមួយឡើយ ហើយនឹងអនុវត្តកិច្ចខិតខំប្រឹងប្រែងសមហេតុផលដើម្បីរក្សាព័ត៌មាននេះឲ្យមានសុវត្ថិភាព។ Caterpillar ទទួលស្គាល់ និងគោរពភាពឯកជនរបស់អតិថិជន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងអ្នកចែកចាយផលិតផល Cat ក្នុងមូលដ្ឋានរបស់លោកអ្នក។

## ប្រតិបត្តិការនៅកន្លែងផ្ទុះសម្រាប់ វិទ្យុតំណផលិតផល

**⚠ ការព្រមាន**

**កំណត់សម្គាល់៖ បរិក្ខាររបស់យើងអាចត្រូវបានបំពាក់ដោយឧបករណ៍ប្រាស្រ័យទាក់ទង Caterpillar Product Link ។ នៅពេលកំពុងប្រើប្រាស់កិបអគ្គិសនីសម្រាប់ប្រតិបត្តិការបំផ្ទុះ ឧបករណ៍ប្រេកង់វិទ្យុអាចរំខានដល់កិបអគ្គិសនីសម្រាប់ធ្វើឲ្យផ្ទុះ ដែលអាចបណ្តាលឲ្យរងរបួសធ្ងន់ធ្ងរ ឬស្លាប់។ ឧបករណ៍ទាក់ទង Product Link គួរតែបិទនៅក្នុងចម្ងាយដែលបានកំណត់ស្ថិតក្រោមសេក្តីតម្រូវបទប្បញ្ញត្តិមូលដ្ឋាន ឬថ្នាក់ជាតិ។ ក្នុងករណីមិនមានសេក្តីតម្រូវបទប្បញ្ញត្តិ ក្រុមហ៊ុន Caterpillar សូមណែនាំឲ្យអ្នកប្រើប្រាស់ចុងក្រោយ អនុវត្តតាមការវាយតម្លៃហានិភ័យផ្ទាល់ខ្លួនរបស់ពួកគេដើម្បីកំណត់ចម្ងាយប្រតិបត្តិការដែលមានសុវត្ថិភាព។**

---

ប្រសិនបើចាំបាច់ វិធីសាស្រ្តដែលបានលើកឡើងខាងក្រោមនេះប្រើដើម្បីបិទឧបករណ៍ទំនាក់ទំនង Cat Product Link។

- ផ្តាច់ឧបករណ៍ទំនាក់ទំនង Cat Product Link ចេញពីប្រភពថាមពលមេ។ សកម្មភាពនេះត្រូវបានអនុវត្តដោយផ្តាច់ខ្សែភ្លើងនៅត្រង់វិទ្យុ Product Link។

# ព័ត៌មានអនុលោមតាមបទប្បញ្ញត្តិ

# សមាសភាពហ្វ្រេកង់វិទ្យុ

i08470735

## Product Link
(PLG601 – បើមាន)

**កូដ SMCS៖** 7490; 7606

តារាងទី 1

| ម៉ូដែល | លេខគ្រឿងបន្លាស់ Cat |
|---|---|
| PLG601 | N/A |

---

សម្គាល់

ការផ្សព្វផ្សាយព័ត៌មានដោយប្រើឧបករណ៍ទាក់ទង Caterpillar Product Link គឺអនុលោមទៅតាមសេចក្តីតម្រូវខាងផ្លូវច្បាប់។ សេចក្តីតម្រូវផ្នែកច្បាប់អាចខុសគ្នាៗគ្នាទៅតាមទីកន្លែងផ្សេងគ្នា រួមទាំងការអនុញ្ញាតឲ្យប្រើប្រាស់ហ្វ្រេកង់វិទ្យុផងដែរ។ ការប្រើឧបករណ៍ទំនាក់ទំនង Cat Product Link ត្រូវតែកំណត់ចំពោះទីតាំងទាំងឡាយណាដែលបានបំពេញតាមសេចក្តីតម្រូវផ្នែកច្បាប់ទាំងអស់ក្នុងការប្រើឧបករណ៍ទាក់ទង Cat Product Link និងបណ្តាញទំនាក់ទំនង។

ប្រសិនបើគ្រឿងបរិក្ខារត្រូវគ្នានឹងឧបករណ៍ទំនាក់ទំនង Cat Product Link ស្ថិតនៅក្នុងឬប្តូរទីតាំងទៅកាន់ទីតាំងដែល (i) មិនស្របនឹងសេចក្តីតម្រូវខាងផ្លូវច្បាប់ ឬ (ii) ការបញ្ជូន ឬ ការដំណើរការព័ត៌មាននោះកាត់ទីកន្លែងច្រើនដែលមិនស្របច្បាប់ Caterpillar សូមប្រកាសបដិសេធនូវការទទួលខុសត្រូវទាំងឡាយដែលពាក់ព័ន្ធនឹងការខកខានក្នុងការអនុលោមតាមច្បាប់ ហើយ Caterpillar អាចផ្តាច់ការបញ្ជូនព័ត៌មានពីគ្រឿងបរិក្ខារនោះ។

ចូរប្រឹក្សាជាមួយអ្នកចែកចាយផលិតផល Cat របស់លោកអ្នក ប្រសិនបើមានសំណួរ ឬ កង្វល់អំពីប្រតិបត្តិការប្រព័ន្ធ Product Link នៅក្នុងប្រទេសមួយជាក់លាក់។

---

**ឯកសារយោង៖** ដើម្បីជ្រាបនូវព័ត៌មានបន្ថែម ចូរអានកូនសៀវភៅណែនាំដំណើរការ និងការថែទាំជួសជុលសម្រាប់ផលិតផលរបស់លោកអ្នក។

## សេចក្តីជូនដំណឹងវិញ្ញាបនបត្រ

### សេចក្តីជូនដំណឹងរបស់ប្រទេសកាណាដាចំពោះអ្នកប្រើប្រាស់

ឧបករណ៍នេះអនុលោមតាមអាជ្ញាប័ណ្ណឧស្សាហកម្មកាណាដាលើកលែងតែ RSS ។ ប្រតិបត្តិការ គឺស្ថិតនៅក្រោមលក្ខខណ្ឌពីរខាងក្រោម៖

- ឧបករណ៍នេះអាចបង្កឲ្យមានការរំខាន
- ឧបករណ៍នេះត្រូវតែទទួលយកការរំខានទាំងឡាយ ដែលរួមមានការរំខានដែលអាចបណ្តាលឲ្យ ប្រតិបត្តិការឧបករណ៍នេះដំណើរការមិនស្រួល។

### កំណត់សម្គាល់ FCC

ឧបករណ៍នេះអនុលោមតាមផ្នែកទី 15 នៃបទប្បញ្ញត្តិ FCC ។ ប្រតិបត្តិការគឺស្ថិតនៅក្រោមលក្ខខណ្ឌពីរខាងក្រោម៖

- ឧបករណ៍នេះអាចនឹងមិនបង្កឲ្យមានការរំខានវិទ្យុទាក់ទងដែលបង្កគ្រោះថ្នាក់ឡើយ។
- ឧបករណ៍នេះត្រូវតែទទួលយកការរំខានទាំងឡាយ រួមទាំងការរំខានដែលអាចបង្កឲ្យមាន ដំណើរការមិនស្រួល។

បរិក្ខារនេះត្រូវបានសាកល្បង ហើយត្រូវបានរកឃើញថាបានអនុលោមតាមដែនកំណត់ឧបករណ៍ឌីជីថលថ្នាក់ B តាមផ្នែកទី 15 នៃបទប្បញ្ញត្តិ FCC ។ ដែនកំណត់ទាំងនេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ការការពារសមស្របចំពោះការរំខានវិទ្យុទាក់ទងដែលបង្កគ្រោះថ្នាក់នៅក្នុងការដំឡើងតាមលំនៅឋាន។ គ្រឿងបរិក្ខារនេះបង្កើត ប្រើប្រាស់ និងអាចបញ្ចេញរលកថាមពលហ្វ្រេកង់វិទ្យុ ប្រសិនបើមិនបានដំឡើងឬប្រើប្រាស់គ្រឿងបរិក្ខារនេះឲ្យស្របតាមការណែនាំទេ វាអាចបង្កការរំខានប្រកបដោយគ្រោះថ្នាក់ដល់ទំនាក់ទំនងវិទ្យុ។ ទោះយ៉ាងណាក៏ដោយ មិនមានការធានាថាការរំខាននឹងមិនកើតឡើងនៅក្នុងការដំឡើងជាពិសេសឡើយ។ ប្រសិនបើគ្រឿងបរិក្ខារនេះពិតជាបង្កការរំខានប្រកបដោយគ្រោះថ្នាក់ចំពោះការទទួលសញ្ញាវិទ្យុ ឬទូរទស្សន៍ដែលអាចកំណត់ដោយការមួលបិទនិងបើកគ្រឿងបរិក្ខារ នោះអ្នកប្រើប្រាស់ត្រូវលើកទឹកចិត្តឲ្យព្យាយាម

កែតម្រូវការរំខាននេះតាមវិធានការមួយ ឬច្រើនដូចខាងក្រោម៖

- ប្តូរទិស ឬប្តូរទីតាំងអង់តែនទទួល
- បង្កើនគម្លាតរវាងបរិក្ខារ និងឧបករណ៍ទទួល
- ភ្ជាប់គ្រឿងបរិក្ខារនេះទៅក្នុងព្រីភ្លើងមួយនៅលើសៀគ្វីខុសពីកន្លែងដែលឧបករណ៍ទទួលត្រូវតភ្ជាប់
- ពិគ្រោះជាមួយអ្នកចែកចាយ ឬអ្នកបច្ចេកទេសវិទ្យុ / ទូរទស្សន៍ដែលមានបទពិសោធន៍ដើម្បីស្នើសុំជំនួយ

ការផ្លាស់ប្តូរ ឬការកែប្រែឧបករណ៍នេះដោយគ្មានការអនុញ្ញាតពីក្រុមហ៊ុន Caterpillar អាចនឹងធ្វើឲ្យបាត់បង់សិទ្ធិប្រើប្រាស់ឧបករណ៍នេះ។

i08470736

## Product Link
(PLG641 – បើមាន)

**កូដ SMCS៖** 7490; 7606

តារាង 2

| ម៉ូដែល | លេខគ្រឿងបន្លាស់ Cat |
|---|---|
| PLG641 | 491-7590 |

សម្គាល់
ការផ្សព្វផ្សាយព័ត៌មានដោយប្រើឧបករណ៍ទាក់ទង Caterpillar Product Link គឺអនុលោមទៅតាមសេចក្តីតម្រូវខាងផ្លូវច្បាប់។ សេចក្តីតម្រូវផ្នែកច្បាប់អាចខុសគ្នាៗគ្នាទៅតាមទីកន្លែងផ្សេងគ្នា រួមទាំងការអនុញ្ញាតឲ្យប្រើប្រាស់ប្រេកង់វិទ្យុផងដែរ។ ការប្រើឧបករណ៍ទំនាក់ទំនង Cat Product Link ត្រូវតែកំណត់ចំពោះទីតាំងទាំងឡាយណាដែលបានបំពេញតាមសេចក្តីតម្រូវផ្នែកច្បាប់ទាំងអស់ក្នុងការប្រើឧបករណ៍ទាក់ទង Cat Product Link និងបណ្តាញទំនាក់ទំនង។

ប្រសិនបើគ្រឿងបរិក្ខារត្រូវគ្នានឹងឧបករណ៍ទំនាក់ទំនង Cat Product Link ស្ថិតនៅក្នុងឬប្តូរទីតាំងទៅកាន់ទីតាំងដែល (i) មិនស្របនឹងសេចក្តីតម្រូវខាងផ្លូវច្បាប់ ឬ (ii) ការបញ្ជូន ឬ ការដំណើរការព័ត៌មាននោះកាត់ទីកន្លែងច្រើនដែលមិនស្របច្បាប់ Caterpillar សូមប្រកាសបដិសេធនូវការទទួលខុសត្រូវទាំងឡាយដែលពាក់ព័ន្ធនឹងការខកខានក្នុងការអនុលោមតាមច្បាប់ ហើយ Caterpillar អាចផ្តាច់ការបញ្ជូនព័ត៌មានពីគ្រឿងបរិក្ខារនោះ។

ចូរពិគ្រោះជាមួយឈ្មួញចែកចាយ Cat អំពីសំណួរដែលពាក់ព័ន្ធនឹងប្រតិបត្តិការប្រព័ន្ធ Product Link នៅក្នុងប្រទេសដែលតម្រូវជាពិសេស។

**ឯកសារយោង៖** ដើម្បីជ្រាបនូវព័ត៌មានបន្ថែម ចូរអានកូនសៀវភៅណែនាំដំណើរការ និងការថែទាំជួសជុលសម្រាប់ផលិតផលរបស់លោកអ្នក។

## sDoC

**(សេចក្តីប្រកាសអនុលោមភាពសម្រាយ)**

## សហភាពអឺរ៉ុប

**Caterpillar Inc. 100 NE Adams Peoria, IL 61529 USA**

ត្រង់ន័យនេះ ក្រុមហ៊ុន Caterpillar Inc. សូមប្រកាសថាគ្រឿងបរិក្ខារវិទ្យុនេះអនុលោមតាមសេចក្តីបង្គាប់លេខ “2014/53/EU” ។ អត្ថបទពេញលេញស្តីពីសេចក្តីប្រកាសអនុលោមភាពអឺរ៉ុបមាននៅលើអាសយដ្ឋានគេហទំព័រដូចតទៅនេះ៖

https://www.cat.com/radio-compliance

**ក្រុមហ៊ុន Caterpillar សូមជម្រាបថាលោកអ្នកទទួលបានសេចក្តីប្រកាសអនុលោមភាពនេះភ្លាមបន្ទាប់ពីទិញ។**

## ព័ត៌មានលម្អិត

**ការព្រមាន**

**កំណត់សម្គាល់៖ បរិក្ខាររបស់យើងអាចត្រូវបានបំពាក់ដោយឧបករណ៍ប្រាស្រ័យទាក់ទង Caterpillar Product Link ។ នៅពេលកំពុងប្រើប្រាស់កិបអគ្គិសនីសម្រាប់ប្រតិបត្តិការបំផ្ទុះ ឧបករណ៍ប្រេកង់វិទ្យុអាចរំខានដល់កិបអគ្គិសនីសម្រាប់ធ្វើឲ្យផ្ទុះ ដែលអាចបណ្តាលឲ្យរងរបួសធ្ងន់ធ្ងរ ឬស្លាប់។ ឧបករណ៍ទាក់ទង Product Link គួរតែបិទនៅក្នុងចម្ងាយដែលបានកំណត់ស្ថិតក្រោមសេក្តីតម្រូវបទប្បញ្ញត្តិមូលដ្ឋាន ឬថ្នាក់ជាតិ។ ក្នុងករណីមិនមានសេក្តីតម្រូវបទប្បញ្ញត្តិ ក្រុមហ៊ុន Caterpillar សូមណែនាំឲ្យអ្នកប្រើប្រាស់ចុងក្រោយ អនុវត្តតាមការវាយតម្លៃហានិភ័យផ្ទាល់ខ្លួនរបស់ពួកគេដើម្បីកំណត់ចម្ងាយប្រតិបត្តិការដែលមានសុវត្ថិភាព។**

ព័ត៌មានលម្អិតនៃឧបករណ៍ទាក់ទង Cat Product Link ខាងក្រោមនេះមានផ្តល់ជូនដើម្បីជួយធ្វើការវាយតម្លៃអំពីគ្រោះថ្នាក់ដែលពាក់ព័ន្ធ និងដើម្បីធានានូវអនុលោមភាពតាមបទប្បញ្ញត្តិក្នុងមូលដ្ឋានទាំងអស់៖

តារាង 3

| ព័ត៌មានលម្អិតឧបករណ៍បញ្ជូន | | |
|---|---|---|
| ម៉ូដែលវិទ្យុ | លំដាប់ប្រេកង់ឧបករណ៍បញ្ជូន | ថាមពលនឧបករណ៍បញ្ជូន |
| PLG641 | 824 MHz – 849 MHz | 0.5W typical, 2W max |
| | 880 MHZ – 915 MHz | |
| | 1710 MHz – 1755 MHz | |
| | 1850 MHz – 1910 MHz | |
| | 1920 MHz – 1980 MHz | |
| | 2110 MHz – 2170 MHz | |

តារាង 4

| កម្លាំងវ៉ុលត៍ប្រតិបត្តិការនិងទំនាញចរន្ត | | |
|---|---|---|
| ម៉ូដែល | លំដាប់កម្លាំងវ៉ុល | ការទាញចរន្តអតិបរមា |
| PLG641 | 9 – 32V | 500mA – 150mA |

## សេចក្តីជូនដំណឹងវិញ្ញាបនបត្រ

### សេចក្តីជូនដំណឹងរបស់ប្រទេសកាណាដាចំពោះអ្នកប្រើប្រាស់

ឧបករណ៍នេះអនុលោមតាមអាជ្ញាបណ្ណឧស្សាហកម្មកាណាដា លើកលែងតែ RSS ។ ប្រតិបត្តិការ គឺស្ថិតនៅក្រោមលក្ខខណ្ឌពីរខាងក្រោម៖

- ឧបករណ៍នេះមិនអាចបង្កការរំខានឡើយ។
- ឧបករណ៍នេះត្រូវតែទទួលយកការរំខានទាំងឡាយ ដែលរួមមានការរំខានដែលអាចបណ្តាលឲ្យ ប្រតិបត្តិការឧបករណ៍នេះដំណើរការមិនស្រួល។

## កំណត់សម្គាល់ FCC

ឧបករណ៍នេះអនុលោមតាមផ្នែកទី 15 នៃបទប្បញ្ញត្តិ FCC ។ ប្រតិបត្តិការគឺស្ថិតនៅក្រោមលក្ខខណ្ឌពីរខាងក្រោម៖

- ឧបករណ៍នេះអាចនឹងមិនបង្កឲ្យមានការរំខានវិទ្យុទាក់ទងដែលបង្កគ្រោះថ្នាក់ឡើយ។
- ឧបករណ៍នេះត្រូវតែទទួលយកការរំខានទាំងឡាយ រួមទាំងការរំខានដែលអាចបង្កឲ្យមាន ដំណើរការមិនស្រួល។

បរិក្ខារនេះត្រូវបានសាកល្បង ហើយត្រូវបានរកឃើញថាបានអនុលោមតាមដែនកំណត់ឧបករណ៍ឌីជីថលថ្នាក់ B តាមផ្នែកទី 15 នៃបទប្បញ្ញត្តិ FCC ។ ដែនកំណត់ទាំងនេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ការការពារសមស្របចំពោះការរំខានវិទ្យុទាក់ទងដែលបង្កគ្រោះថ្នាក់នៅក្នុងការដំឡើងតាមលំនៅឋាន។ គ្រឿងបរិក្ខារនេះបង្កើត ប្រើប្រាស់ និងអាចបញ្ចេញរលកថាមពលហ្វ្រេកង់វិទ្យុ ប្រសិនបើមិនបានដំឡើងឬប្រើប្រាស់គ្រឿងបរិក្ខារនេះឲ្យស្របតាមការណែនាំទេ វាអាចបង្កការរំខានប្រកបដោយគ្រោះថ្នាក់ដល់ទំនាក់ទំនងវិទ្យុ។ ទោះយ៉ាងណាក៏ដោយ មិនមានការធានាថាការរំខាននឹងមិនកើតឡើងនៅក្នុងការដំឡើងជាពិសេសឡើយ។ ប្រសិនបើបរិក្ខារនេះបណ្តាលឲ្យមានការរំខានដែលបង្កគ្រោះថ្នាក់ចំពោះការទទួលសញ្ញាវិទ្យុ ឬទូរទស្សន៍ដែលអាចកំណត់បានដោយការបិទ និងបើកបរិក្ខារ អ្នកប្រើប្រាស់ត្រូវបានលើកទឹកចិត្តឲ្យព្យាយាមកែប្រែការរំខានដោយវិធានការមួយ ឬច្រើនដូចខាងក្រោម៖

- ប្តូរទិស ឬប្តូរទីតាំងអង់តែនទទួល
- បង្កើនគម្លាតរវាងបរិក្ខារ និងឧបករណ៍ទទួល
- ភ្ជាប់គ្រឿងបរិក្ខារនេះទៅក្នុងព្រីភ្លើងមួយនៅលើសៀគ្វីខុសពីកន្លែងដែលឧបករណ៍ទទួលត្រូវតភ្ជាប់
- ពិគ្រោះជាមួយអ្នកចែកចាយ ឬអ្នកបច្ចេកទេសវិទ្យុ / ទូរទស្សន៍ដែលមានបទពិសោធន៍ដើម្បីស្នើសុំជំនួយ

ការផ្លាស់ប្តូរ ឬការកែប្រែឧបករណ៍នេះដោយគ្មានការអនុញ្ញាតពីក្រុមហ៊ុន Caterpillar អាចនឹងធ្វើឲ្យបាត់បង់សិទ្ធិប្រើប្រាស់ឧបករណ៍នេះ។

i08470742

# Product Link
(PLG641V2 – បើមាន)

**កូដ SMCS៖** 7490; 7606

តារាង 5

| ម៉ូដែល | លេខគ្រឿងបន្លាស់ Cat |
|---|---|
| PLG641V2 | 569-3109 |

---

សម្គាល់

ការផ្សព្វផ្សាយព័ត៌មានដោយប្រើឧបករណ៍ទាក់ទង Caterpillar Product Link គឺអនុលោមទៅតាមសេចក្តីតម្រូវខាងផ្លូវច្បាប់។ សេចក្តីតម្រូវផ្នែកច្បាប់អាចខុសគ្នាៗគ្នាទៅតាមទីកន្លែងផ្សេងគ្នា រួមទាំងការអនុញ្ញាតឲ្យប្រើប្រាស់ហ្វ្រេកង់វិទ្យុផងដែរ។ ការប្រើឧបករណ៍ទំនាក់ទំនង Cat Product Link ត្រូវតែកំណត់ចំពោះទីតាំងទាំងឡាយណាដែលបានបំពេញតាមសេចក្តីតម្រូវផ្នែកច្បាប់ទាំងអស់ក្នុងការប្រើឧបករណ៍ទាក់ទង Cat Product Link និងបណ្តាញទំនាក់ទំនង។

ប្រសិនបើគ្រឿងបរិក្ខារត្រូវគ្នានឹងឧបករណ៍ទំនាក់ទំនង Cat Product Link ស្ថិតនៅក្នុងឬប្តូរទីតាំងទៅកាន់ទីតាំងដែល (i) មិនស្របនឹងសេចក្តីតម្រូវខាងផ្លូវច្បាប់ ឬ (ii) ការបញ្ជូន ឬ ការដំណើរការព័ត៌មាននោះកាត់ទីកន្លែងច្រើនដែលមិនស្របច្បាប់ Caterpillar សូមប្រកាសបដិសេធនូវការទទួលខុសត្រូវទាំងឡាយដែលពាក់ព័ន្ធនឹងការខកខានក្នុងការអនុលោមតាមច្បាប់ ហើយ Caterpillar អាចផ្តាច់ការបញ្ជូនព័ត៌មានពីគ្រឿងបរិក្ខារនោះ។

ចូរប្រឹក្សាជាមួយអ្នកចែកចាយផលិតផល Cat របស់លោកអ្នក ប្រសិនបើមានសំណួរ ឬ កង្វល់អំពីប្រតិបត្តិការប្រព័ន្ធ Product Link នៅក្នុងប្រទេសមួយជាក់លាក់។

---

**ឯកសារយោង៖** ដើម្បីជ្រាបនូវព័ត៌មានបន្ថែម ចូរអានកូនសៀវភៅណែនាំដំណើរការ និងការថែទាំជួសជុលសម្រាប់ផលិតផលរបស់លោកអ្នក។

## sDoC

**(សេចក្តីប្រកាសអនុលោមភាពសម្រាយ)**

## សហភាពអឺរ៉ុប

**Caterpillar Inc. 100 NE Adams Peoria, IL 61529 USA**

ត្រង់ន័យនេះ ក្រុមហ៊ុន Caterpillar Inc. សូមប្រកាសថាគ្រឿងបរិក្ខារវិទ្យុនេះអនុលោមតាមសេចក្តីបង្គាប់លេខ “2014/53/EU” ។ អត្ថបទពេញលេញស្តីពីសេចក្តីប្រកាសអនុលោមភាពអឺរ៉ុបមាននៅលើអាសយដ្ឋានគេហទំព័រដូចតទៅនេះ៖

https://www.cat.com/radio-compliance

## ចក្រភពអង់គ្លេស

**Caterpillar Inc. 100 NE Adams Peoria, IL 61529 USA**

ត្រង់ន័យនេះ ក្រុមហ៊ុន Caterpillar Inc. សូមប្រកាសថាគ្រឿងបរិក្ខារវិទ្យុនេះអនុលោមតាមលក្ខខណ្ឌតម្រូវដែលកំណត់ដោយច្បាប់ពាក់ព័ន្ធ។ អត្ថបទពេញលេញអំពីសេចក្តីប្រកាសអនុលោមភាពចក្រភពអង់គ្លេសមាននៅលើអាសយដ្ឋានគេហទំព័រដូចទៅនេះ៖

https://www.cat.com/radio-compliance

ក្រុមហ៊ុន **Caterpillar** សូមជម្រាបថាលោកអ្នកទទួលបានសេចក្តីប្រកាសអនុលោមភាពនេះភ្លាមបន្ទាប់ពីទិញ។

## ព័ត៌មានលម្អិត

**⚠ ការព្រមាន**

**កំណត់សម្គាល់៖ បរិក្ខាររបស់យើងអាចត្រូវបានបំពាក់ដោយឧបករណ៍ប្រាស្រ័យទាក់ទង Caterpillar Product Link ។ នៅពេលកំពុងប្រើប្រាស់កិបអគ្គិសនីសម្រាប់ប្រតិបត្តិការបំផ្ទុះ ឧបករណ៍ប្រេកង់វិទ្យុអាចរំខានដល់កិបអគ្គិសនីសម្រាប់ធ្វើឲ្យផ្ទុះ ដែលអាចបណ្តាលឲ្យរងរបួសធ្ងន់ធ្ងរ ឬស្លាប់។ ឧបករណ៍ទាក់ទង Product Link គួរតែបិទនៅក្នុងចម្ងាយដែលបានកំណត់ស្ថិតក្រោមសេក្តីតម្រូវបទប្បញ្ញត្តិមូលដ្ឋាន ឬថ្នាក់ជាតិ។ ក្នុងករណីមិនមានសេក្តីតម្រូវបទប្បញ្ញត្តិ ក្រុមហ៊ុន Caterpillar សូមណែនាំឲ្យអ្នកប្រើប្រាស់ចុងក្រោយ អនុវត្តតាមការវាយតម្លៃហានិភ័យផ្ទាល់ខ្លួនរបស់ពួកគេដើម្បីកំណត់ចម្ងាយប្រតិបត្តិការដែលមានសុវត្ថិភាព។**

ព័ត៌មានលម្អិតអំពីឧបករណ៍ទំនាក់ទំនង PLG641V2 មានផ្តល់ជូនជាជំនួយក្នុងការវាយតម្លៃអំពីគ្រោះអន្តរាយពាក់ព័ន្ធណាមួយ និងដើម្បីធានានូវការអនុលោមតាមបទប្បញ្ញត្តិក្នុងមូលដ្ឋានទាំងអស់៖

តារាង 6

| ព័ត៌មានលម្អិតឧបករណ៍បញ្ជូន | | |
|---|---|---|
| ម៉ូដែលវិទ្យុ | លំដាប់ប្រេកង់ឧបករណ៍បញ្ជូន | ថាមពលនឧបករណ៍បញ្ជូន |
| PLG641V2 | 824 MHz – 849 MHz (Uplink) | 6W អតិ |
| | 869 MHz – 894 MHz (Downlink) | |
| | 1710 MHz – 1755 MHz (Uplink) | |
| | 1850 MHz – 1910 MHz (Uplink) | |
| | 1930 MHz – 1990 MHz (Downlink) | |
| | 2110 MHz – 2115 MHz (Downlink) | |

## សេចក្តីជូនដំណឹងវិញ្ញាបនបត្រ

### សេចក្តីជូនដំណឹងរបស់ប្រទេសកាណាដាចំពោះអ្នកប្រើប្រាស់

ឧបករណ៍នេះអនុលោមតាមអាជ្ញាបណ្ណឧស្សាហកម្មកាណាដា លើកលែងតែ RSS ។ ប្រតិបត្តិការ គឺស្ថិតនៅក្រោមលក្ខខណ្ឌពីរខាងក្រោម៖

- ឧបករណ៍នេះអាចបង្កឲ្យមានការរំខាន
- ឧបករណ៍នេះត្រូវតែទទួលយកការរំខានទាំងឡាយ ដែលរួមមានការរំខានដែលអាចបណ្តាលឲ្យ ប្រតិបត្តិការឧបករណ៍នេះដំណើរការមិនស្រួល។

ឧបករណ៍នេះរចនាឡើងដើម្បីប្រតិបត្តិការជាមួយអង់តែនមួយ ឬច្រើនដែលបានរៀបរាប់ខាងក្រោម៖

**អង់តែនសម្រាប់ប្រើ៖**

- 588-9248 អង់តែនជាជើងភ្ជាប់រឹង
- 589-1358 អង់តែនជាជើងភ្ជាប់ស្អិត

### កំណត់សម្គាល់ FCC

ឧបករណ៍នេះអនុលោមតាមផ្នែកទី 15 នៃបទប្បញ្ញត្តិ FCC ។ ប្រតិបត្តិការគឺស្ថិតនៅក្រោមលក្ខខណ្ឌពីរខាងក្រោម៖

- ឧបករណ៍នេះអាចនឹងមិនបង្កឲ្យមានការរំខានវិទ្យុទាក់ទងដែលបង្កគ្រោះថ្នាក់ឡើយ។
- ឧបករណ៍នេះត្រូវតែទទួលយកការរំខានទាំងឡាយ រួមទាំងការរំខានដែលអាចបង្កឲ្យមាន ដំណើរការមិនស្រួល។

បរិក្ខារនេះត្រូវបានសាកល្បង ហើយត្រូវបានរកឃើញថាបានអនុលោមតាមដែនកំណត់ឧបករណ៍ឌីជីថលថ្នាក់ B តាមផ្នែកទី 15 នៃបទប្បញ្ញត្តិ FCC ។ ដែនកំណត់ទាំងនេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ការការពារសមស្របចំពោះការរំខានវិទ្យុទាក់ទងដែលបង្កគ្រោះថ្នាក់នៅក្នុងការដំឡើងតាមលំនៅឋាន។ គ្រឿងបរិក្ខារនេះបង្កើត ប្រើប្រាស់ និងអាចបញ្ចេញរលកថាមពលប្រេកង់វិទ្យុ ប្រសិនបើមិនបានដំឡើងឬប្រើប្រាស់គ្រឿងបរិក្ខារនេះឲ្យស្របតាមការណែនាំទេ វាអាចបង្កការរំខានប្រកបដោយគ្រោះថ្នាក់ដល់ទំនាក់ទំនងវិទ្យុ។ ទោះយ៉ាងណាក៏ដោយ មិនមានការធានាថាការរំខាននឹងមិនកើតឡើងនៅក្នុងការដំឡើងជាពិសេសឡើយ។ ប្រសិនបើបរិក្ខារនេះបណ្តាលឲ្យមានការរំខានដែលបង្កគ្រោះថ្នាក់ចំពោះការទទួលសញ្ញាវិទ្យុ ឬទូរទស្សន៍ដែលអាចកំណត់បានដោយការបិទ និងបើកបរិក្ខារ អ្នកប្រើប្រាស់ត្រូវបានលើកទឹកចិត្តឲ្យព្យាយាមកែប្រែការរំខានដោយវិធានការមួយ ឬច្រើនដូចខាងក្រោម៖

- ប្តូរទិស ឬប្តូរទីតាំងអង់តែនទទួល
- បង្កើនគម្លាតរវាងបរិក្ខារ និងឧបករណ៍ទទួល
- ភ្ជាប់គ្រឿងបរិក្ខារនេះទៅក្នុងព្រីភ្លើងមួយនៅលើសៀគ្វីខុសពីកន្លែងដែលឧបករណ៍ទទួលត្រូវតភ្ជាប់
- ពិគ្រោះជាមួយអ្នកចែកចាយ ឬអ្នកបច្ចេកទេសវិទ្យុ / ទូរទស្សន៍ដែលមានបទពិសោធន៍ដើម្បីស្នើសុំជំនួយ

ការផ្លាស់ប្តូរ ឬការកែប្រែឧបករណ៍នេះដោយគ្មានការអនុញ្ញាតពីក្រុមហ៊ុន Caterpillar អាចនឹងធ្វើឲ្យបាត់បង់សិទ្ធិប្រើប្រាស់ឧបករណ៍នេះ។

## សញ្ញាសម្គាល់វិញ្ញាបនបត្រ

CNC **អាហ្សង់ទីន – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើ នៅក្នុងប្រទេសអាហ្សង់ទីន។ លេខសម្គាល់វិញ្ញាបនបត្រ៖**
**EX-2020-35132502- -APN-REYS#ENACOM.CT:24771. 200529172806.92**

**អូស្ត្រាលី – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសអូស្ត្រាលី។**

**បារ៉ែន** – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសបារ៉ែន។ លេខអនុម័ត៖ APV-TAC-0520-TRM-17

**បេលី** – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសបេលី។ ស្លាកសម្គាល់អត្តសញ្ញាណ PUC៖ PUC/CI/0732020/BZE

**បេណាំង** – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសបេណាំង។ លេខឯកសារអនុម័ត៖ DAERT-2020-05-29GJO- MCMVM-1WCGO

**បូលីវី** – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសបូលីវី។ លេខសម្គាល់វិញ្ញាបនបត្រ៖ ATT-DJ-RA-H-TL LP 396/2020

**ប៊ុតស្វាណា** – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសប៊ុតស្វាណា។ លេខវិញ្ញាបនបត្រអនុម័តប្រភេទ៖ BOCRA/ TA/2020/5704

**ព្រុយណេ – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសព្រុយណេ។ លេខសម្គាល់វិញ្ញាបនបត្រ៖ DTA-006448**

**បួគីណាហ្វាសូ** – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសបួគីណាហ្វាសូ។ លេខវិញ្ញាបនបត្រអនុម័ត៖ 000106/ ARCEP/SG/DGSN

**កម្ពុជា** – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសកម្ពុជា។ TRC ID: 0193-2020-41V2

**ឈីលី– ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសឈីលី។ លេខ SUBTEL 266708 de 23.10.202**

**កូឡុំប៊ី** – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសកូឡុំប៊ី។ លេខដំណោះស្រាយ CRC៖ 2020512830

**កុងហ្គោ សាធារណរដ្ឋ** – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងសាធារណរដ្ឋកុងហ្គោ។ លេខវិញ្ញាបនបត្រ៖ 100/ARPCE-DG/DAJI/DRSCE/20

**អេក្វាទ័រ** – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសអេក្វាទ័រ។ លេខសម្គាល់វិញ្ញាបនបត្រ៖ ARCOTEL-2020-029365

**អេហ្ស៊ីប** – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសអេហ្ស៊ីប។ ECA/TA/No: 1847/2020

**ហ្គាំប៊ី**– ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសហ្គាំប៊ី។ លេខអនុម័តប្រភេទ៖ TA-0001343

**ហ្គាណា** – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសហ្គាណា។ លេខសម្គាល់ផលិតផល NCA៖ SRO-1M- 7E4-X85

**ហុងកុង – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅហុងកុង។ លេខវិញ្ញាបនបត្រ៖ HK0012002324**

**កូតឌីវ័រ (Ivory Coast)** – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសកូតឌីវ័រ។ លេខវិញ្ញាបនបត្រ៖ 3216/DG/DRCT/DCO/SHO

**ម៉ាល់ឌីវ** – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសម៉ាល់ឌីវ។ លេខវិញ្ញាបនបត្រអនុម័តប្រភេទ៖ CAM- TAC2020-22

**ម៉ាលី** – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសម៉ាលី។ លេខវិញ្ញាបនបត្រ៖ 2020-05-050/AMRTP-P

**ម៉ូរីតានី**– ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសម៉ូរីតានី។ លេខវិញ្ញាបនបត្រ៖ 0794/ARE/2020

**ម៉ារ៉ុក** – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសម៉ារ៉ុក។ លេខវិញ្ញាបនបត្រ៖ ANRT/DTEC/DAA/SAG/ APP/OR/304/2020

**ណាមីប៊ី**– ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសណាមីប៊ី។ លេខសម្គាល់អនុម័តប្រភេទ៖ 2020/8119

**នីហ្សេ** – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសនីហ្សេ។ លេខសម្គាល់វិញ្ញាបនបត្រ៖ HOMO-0043/ARCEP/DG/2020

**នីហ្សេរីយ៉ា**– ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសនីហ្សេរីយ៉ា។ NCC ID No. NCC/TSNI/WN/TA/CERT/3576/2020

**ប៉េរូ** – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសប៉េរូ។ លេខសម្គាល់វិញ្ញាបនបត្រ៖ TRFM47740

**ហ្វីលីពីន – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសហ្វីលីពីន។ លេខសម្គាល់វិញ្ញាបនបត្រអនុម័តប្រភេទ៖ ESD-CPE-2003586**

**កាតា** – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសកាតា។ លេខសម្គាល់អនុម័តប្រភេទ៖ CRA/SM/2020/S-0004608

**សេណេហ្គាល់** – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសសេណេហ្គាល់។ លេខសម្គាល់វិញ្ញាបនបត្រ៖ 071514/AG/ER

**អាហ្វ្រិកខាងត្បូង – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង។ លេខសម្គាល់វិញ្ញាបនបត្រ៖ TA 2020/6287**

**ស្វ៊ីដង់ខាងត្បូង** – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសស្វ៊ីដង់ខាងត្បូង។ លេខវិញ្ញាបនបត្រអនុម័តប្រភេទ៖ RSS/ NCA/TA/2018/5/145

**ថៃ – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសថៃ។ លេខសម្គាល់វិញ្ញាបនបត្រ៖ B38497- 20**

**តូហ្គោ** – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសតូហ្គោ។ លេខវិញ្ញាបនបត្រ៖ N03/20

**តួកគី** – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសតួកគី។ លេខសម្គាល់វិញ្ញាបនបត្រ៖ 32423510-254.01-E.4034

**UAE** – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុង UAE។ លេខសម្គាល់វិញ្ញាបនបត្រ៖ ER88893/20

**សហរដ្ឋអាមេរិក – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងសហរដ្ឋអាមេរិក។ FCC ID: QIPPLS8-USR4**

**អ៊ុយរូហ្គាយ** – ឧបករណ៍នេះត្រូវអនុម័តឲ្យប្រើនៅក្នុងប្រទេសអ៊ុយរូហ្គាយ។
លេខសម្គាល់វិញ្ញាបនបត្រ៖ VU20200515-005117

# លិបិក្រម

**P**

Product Link (PLG601 – បើមាន) ....................8
  សេចក្តីជូនដំណឹងវិញ្ញាបនបត្រ ....................8
Product Link (PLG641 – បើមាន) ....................8
  សេចក្តីជូនដំណឹងវិញ្ញាបនបត្រ ....................9
  sDoC ....................9
  ព័ត៌មានលម្អិត....................9
Product Link (PLG641V2 – បើមាន)....................10
  សញ្ញាសម្គាល់វិញ្ញាបនបត្រ ....................11
  សេចក្តីជូនដំណឹងវិញ្ញាបនបត្រ ....................11
  sDoC ....................10
  ព័ត៌មានលម្អិត....................11

**ត**

តារាងមាតិកា ....................3

**ទ**

ទិដ្ឋភាពទូទៅរបស់ប្រព័ន្ធ....................7
  ការផ្សព្វផ្សាយទិន្នន័យ....................7
  ប្រតិបត្តិការនៅក្នុងទីតាំងបន្ទុះសម្រាប់វិទ្យុ Product Link....................7

**ប**

បុព្វកថា ....................4
  ព័ត៌មានឯកសារ ....................4
  ការថែទាំជួសជុល ....................4
  ប្រតិបត្តិការ....................4
  សុវត្ថិភាព....................4
ប្រតិបត្តិការ ....................7

**ផ**

ផ្នែកប្រតិបត្តិការ។ ....................7
ផ្នែកសុវត្ថិភាព....................5

**ព**

ព័ត៌មានអនុលោមតាមបទប្បញ្ញត្តិ....................8
ព័ត៌មានអំពីគ្រោះអន្តរាយទូទៅ....................6
  បុព្វកថា....................6
  សេចក្តីផ្តើម ....................6
  ព័ត៌មានសុវត្ថិភាពសំខាន់ៗ ....................2

**ស**

សញ្ញានិងតែមសុវត្ថិភាព ....................5
  តែមផ្សេងៗ ....................5
  សារសុវត្ថិភាព....................5
សមាសភាពប្រេកង់វិទ្យុ....................8

# ព័ត៌មានស្ដីពីគ្រឿងចក្រ និងអ្នកចែកចាយ

កំណត់ចំណាំ៖សម្រាប់ទីតាំងសម្គាល់ផ្លាកលេខគ្រឿងចក្រ សូ ម.មើលផ្នែក "ព័ត៌មានអំពីការកំណត់អត្តសញ្ញាណគ្រឿងចក្រ" នៅក្នុងកូនសៀវភៅណែនាំដំណើរការ និងការថែទាំជួសជុល។

**កាលបរិច្ឆេទប្រគល់៖** ____________________

## ព័ត៌មានស្ដីពីគ្រឿងចក្រ

ម៉ូដែល៖____________________

លេខសម្គាល់ផលិតផល៖ ____________________

លេខសៀរៀលគ្រឿងចក្រ៖ ____________________

លេខសៀរៀលគ្រឿងបញ្ជូន៖ ____________________

លេខសៀរៀលម៉ាស៊ីនភ្លើង៖ ____________________

លេខសៀរៀលគ្រឿងបំពាក់៖ ____________________

ព័ត៌មានគ្រឿងភ្ជាប់៖ ____________________

លេខបរិក្ខារអតិថិជន៖ ____________________

លេខបរិក្ខារអ្នកចែកចាយ៖ ____________________

## ព័ត៌មានអំពីអ្នកចែកចាយ

ឈ្មោះ៖ ____________________ សាខា៖ ____________________

អាសយដ្ឋាន៖ ____________________

____________________

____________________

| | ទំនាក់ទំនងអ្នកចែកចាយ | លេខទូរសព្ទ | ម៉ោង |
|---|---|---|---|
| ផ្នែកលក់៖ | | | |
| គ្រឿងបន្លាស់៖ | | | |
| សេវាកម្ម៖ | | | |

M0075640
©2021 Caterpillar រក្សាសិទ្ធិគ្រប់យ៉ាង

CAT, CATERPILLAR, LET’S DO THE WORK, ឡូហ្គោរៀងៗខ្លួនរបស់ពួកគេ អាសយដ្ឋានពាណិជ្ជកម្ម "Caterpillar Yellow”, the “Power Edge” និង Cat “Modern Hex” ក៏ដូចជាអត្តសញ្ញាណសាជីវកម្ម និងលេខផលិតផលដែលប្រើនៅក្នុងនេះ គឺជាពាណិជ្ជសញ្ញារបស់ក្រុមហ៊ុន Caterpillar ហើយមិនអាចប្រើប្រាស់ដោយគ្មានការអនុញ្ញាតឡើយ។